# សេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល
# ស្តីពី
# របៀបវារៈច្បាប់បច្ចុប្បន្នរបស់កម្ពុជា

យើងខ្ញុំជាអង្គការសង្គមស៊ីវិលនៅកម្ពុជា សាទរនិងតែងតែផ្តល់តម្លៃយ៉ាងខ្លាំងចំពោះកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាលថាជាកត្តាដ៏សំខាន់មួយ ក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ ក្នុងចំណោមតួនាទីជាច្រើនរបស់អង្គការសង្គមស៊ីវិល យើងខ្ញុំដើរតួនាទីជាអ្នកសម្របសម្រួលក្តីបារម្ភរួមពីសាធារណៈជនទៅកាន់រាជរដ្ឋាភិបាល។ នៅក្នុងដំណាក់កាលដ៏សំខាន់ក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជានេះ សកម្មភាពរបស់រាជរដ្ឋាភិបាលនៅមិនទាន់បានបំពេញទៅតាមការសន្យារបស់ខ្លួន ក្នុងការអនុវត្តកំណែទម្រង់ដ៏ចាំបាច់ និងមិនទាន់ឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងតម្រូវការរបស់ពលរដ្ឋខ្លួននៅឡើយទេ។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ដែលគំរាមកំហែង និងកាត់បន្ថយសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជា។

ក្នុងសង្គមលទ្ធិប្រជាធិបតេយ្យដែលមានភាពចាស់ទុំនៅជុំវិញពិភពលោក គេប្រើប្រាស់ការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលនិងភាគីពាក់ព័ន្ធនានាសម្រាប់ជាធនធាន និងជាមធ្យោបាយដ៏សំខាន់ដើម្បីធានាថាគោលការណ៍ច្បាប់នានាបម្រើដល់ផលប្រយោជន៍សាធារណៈ និងប្រទេសជាតិបានយ៉ាងពិតប្រាកដ។ ក្នុងនាមជាអង្គការសង្គមស៊ីវិល ដែលធ្វើការផ្ទាល់និងមានកិច្ចពិភាក្សាជាទៀងទាត់ជាមួយប្រជាពលរដ្ឋជាម្ចាស់ឆ្នោតនិងអ្នកជំនាញបច្ចេកទេស យើងខ្ញុំត្រៀមខ្លួនរួចជាស្រេចដើម្បីជួយរាជរដ្ឋាភិបាលក្នុងការជំរុញរបៀបវារៈកំណែទម្រង់របស់ខ្លួន ដើម្បីលើកកម្ពស់សេរីភាពនិងវិបុលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ អង្គការសង្គមស៊ីវិលអបអរសាទរនិងវាយតម្លៃខ្ពស់ក្នុងការទទួលបានឱកាសបន្ថែមទៀត ដើម្បីផ្តល់ជាគំនិតយោបល់ទៅក្នុងសេចក្តីព្រាងច្បាប់នានា ប៉ុន្តែយើងខ្ញុំមានការព្រួយបារម្ភដោយសារនាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានអនុម័តច្បាប់សំខាន់ៗមួយចំនួនដោយមិនមានការពិគ្រោះយោបល់ ឬមិនបានរួមបញ្ចូលនូវបទប្បញ្ញត្តិនានា ដែលបានលើកឡើងតាមរយៈការពិគ្រោះយោបល់នាពេលកន្លងមក ក៏ដូចជាមិនមានរួមបញ្ចូលនូវសមាសធាតុសម្រាប់ការធ្វើកំណែទម្រង់ ដែលប្រកបដោយអត្ថន័យ។

ក្នុងនាមជាស្ថាប័នដែលធ្វើការលើវិស័យការពារសិទ្ធិមនុស្សលើកកម្ពស់សេរីភាពនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជាតាមមាគ៌ាកំណែទម្រង់ពិតប្រាកដមួយ ទូលព្រះបង្គំយើងខ្ញុំសូមស្នើដូចតទៅ៖

- ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាសូមព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថនរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាព្រះរាជតម្រិះ ក្នុងការមិនឡាយព្រះហស្តលេខាលើសេចក្តីព្រាង**ច្បាប់មូលដ្ឋានទាំងបីពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ** ដោយសារច្បាប់ទាំងបីនេះមានអធម្មនុញ្ញភាពនិងមិនអាចធានាឯករាជ្យភាពនៃអំណាចតុលាការបាន។ ទូលព្រះបង្គំយើងខ្ញុំសូមស្នើព្រះករុណាទ្រង់ជំរុញឲ្យមានការពិនិត្យលើច្បាប់ទាំងនេះឡើងវិញ ដើម្បីធានាឲ្យមានស្ថាប័នតុលាការឯករាជ្យមួយពិតប្រាកដ។

- យើងខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាបោះបង់ចោលនូវបទបញ្ញត្តិទាំងឡាយ ដែលមានក្នុងរបៀបវារៈច្បាប់របស់ខ្លួនដែលគំរាមកំហែងនិងបំបិទបដិមតិ ហើយជំនួសមកវិញនូវការផ្តល់ឱកាសចូលរួមក្នុងកិច្ចពិភាក្សាបែបស្ថាបនាជាមួយភាគីពាក់ព័ន្ធ ដើម្បីបង្កើតគោលនយោបាយដែលបម្រើដល់ប្រយោជន៍សាធារណៈ។
- យើងខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលបង្ហាញសេចក្តីព្រាងច្បាប់ទាំងអស់ឲ្យសាធារណៈជនបានដឹង និងចូលរួមក្នុងការពិគ្រោះយោបល់ប្រកបទៅដោយអត្ថន័យពីសំណាក់ភាគីពាក់ព័ន្ធ ព្រមទាំងបន្តទទួលយកក្តីបារម្ភ ទស្សនៈ និងការយល់ឃើញរបស់ម្ចាស់ឆ្នោតនិងសាធារណៈជន ទៅលើសេចក្តីព្រាងច្បាប់ទាំងនោះ។
- សំណូមពរដល់រាជរដ្ឋាភិបាល៖ ១)ផ្អាកការពិចារណាលើសេចក្តីព្រាង**ច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត** រហូតទាល់តែក្តីកង្វល់នានាត្រូវបានដោះស្រាយគ្រប់គ្រាន់ ២)ផ្តល់ជូនសេចក្តីព្រាងច្បាប់បច្ចុប្បន្ន និង ៣)រៀបចំការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលនិងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពិភាក្សាដកចេញរាល់បទបញ្ញត្តិទាំងអស់ ដែលរំខានឬរំលោភសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្លួន។ សង្គមស៊ីវិលយល់ឃើញថាច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត[1] ដែលស្ថិតក្នុងខ្លឹមសារបច្ចុប្បន្នរំលោភលើការការពារសិទ្ធិមនុស្ស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងអនុសញ្ញាអន្តរជាតិដែលផ្តល់សច្ចាប័នដោយកម្ពុជា[2]។ ច្បាប់នេះនឹងទប់ស្កាត់ជាខ្លាំងដល់សេរីភាពបញ្ចេញមតិនៅកម្ពុជា និងបង្កផលប៉ះពាល់អវិជ្ជ-មានយ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍរបស់ប្រទេស ជាពិសេសភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចរបស់ខ្លួន[3]។
- យើងខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជា៖ ១) ចែករំលែកសេចក្តីព្រាងច្បាប់**ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**បច្ចុប្បន្ន ២) បញ្ចូលបទបញ្ញត្តិដែលជាអនុសាសន៍នាពេលកន្លងមកដោយសង្គមស៊ីវិល និង ៣) ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នភាពបន្ថែមទៀតចំពោះសេចក្តីព្រាងច្បាប់នេះមុន ពេលដែលត្រូវបានដាក់ជូនអនុម័ត។ **ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល**ត្រូវមានចែងយ៉ាងច្បាស់អំពីការការពារអង្គការសមាគមពីការជ្រៀតជ្រែកផ្នែកនយោបាយ។ ការខកខានមិនបានបញ្ចូលការការពារបែបនេះនឹងធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។
- យើងខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាធានាថា **ច្បាប់ស្តីពីសហជីព** មានរួមបញ្ចូលនូវរាល់បទបញ្ញត្តិទាំងអស់ដែលផ្តល់ឲ្យកម្មករ នូវសិទ្ធិបង្កើតសហជីពនិងគោរពសិទ្ធិសេរីភាពនៃការប្រមូលផ្តុំ។ យើងខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលរក្សាការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ និងធានាថាអនុ-សាសន៍របស់ភាគីទាំងនោះ ត្រូវបានដាក់បញ្ចូលក្នុងកំណែច្បាប់ចុងក្រោយ។ ច្បាប់ស្តីពីសហជីពមិនត្រូវរារាំងសិទ្ធិរបស់កម្មករក្នុងការបង្កើតសហជីព ឬរារាំងសិទ្ធិសេរីភាពបង្កើតសមាគមរបស់ពួកគេនោះទេ។
- យើងខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាពិចារណាឡើងវិញលើសេចក្តីព្រាង**ច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម**។ សេចក្តីព្រាងច្បាប់នេះគួរតែរៀបចំធ្វើឡើងវិញដោយមានការពិគ្រោះយោបល់ជាសាធារណៈ ឲ្យបានទូលំទូលាយជាមួយកសិករនៅតាមមូលដ្ឋានដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល

---

[1]សេចក្តីព្រាងច្បាប់ដែលទទួលបានក្រៅផ្លូវការ (លេចចេញ)

[2]សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (មាត្រា២ (១)) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) (មាត្រា១២និង២២)

[3]របាយការណ៍របស់ក្រុមហ៊ុន Dalberg Global Advisors ដែលមានចំណើងជើងថា *បើកចំហរសម្រាប់អាជីវកម្ម? ឥទ្ធិពលនៃការបើកចំហរអ៊ីនធឺណិតមកលើសេដ្ឋកិច្ច* ខែមីនា ឆ្នាំ២០១៤ ដែលអាចរកតាមរយៈគេហទំព័រ www.dalberg.com/documents/Open_for_Business_Dalberg.pdf

និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ ខ្លឹមសារបច្ចុប្បន្នរបស់សេចក្តីព្រាងច្បាប់នេះ បានដាក់បន្ទុកយ៉ាងខ្លាំងលើអ្នកកាន់កាប់ ដីឯកជននិងកសិករនៅតាមមូលដ្ឋានដែលជាម្ចាស់ដីដូចជា ការដាក់ទោសព្រហ្មទណ្ឌ ការដកសិទ្ធិក្នុងការគ្រប់គ្រង និងចាត់ចែងលើកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះនឹងអាចត្រូវបានប្រើប្រាស់សម្រាប់ច្បាមរំលោភយកដីធ្លីរបស់ប្រជាពលរដ្ឋកម្ពុជា និងធ្វើឲ្យធនធានធម្មជាតិវិនាសហិនហោច ព្រមទាំងបណ្តាលឲ្យប្រជាពលរដ្ឋកាន់តែធ្លាក់ចូលជ្រៅក្នុងភាពក្រីក្រ។ ខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះមានលក្ខណៈផ្ទុយទៅ នឹងច្បាប់ភូមិបាល និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូល។

យើងខ្ញុំក៏សូមអំពាវនាវផងដែរដល់ស្ថានទូតបរទេស ដៃគូអភិវឌ្ឍរួមទាំងវិស័យឯកជនឲ្យឆ្លុះបញ្ចាំង និងជំរុញនូវកង្វល់ទាំងនេះ តាមមធ្យោបាយនានាដូចជាការទំនាក់ទំនងជាសាធារណៈនិងឯកជនជាមួយមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាឲ្យកាន់តែមានការអភិវឌ្ឍតាមបែបសង្គមប្រជាធិបតេយ្យ បរិស្ថាននីតិរដ្ឋ ការពង្រឹងសេដ្ឋកិច្ច និងស្ថេរភាពនៅកម្ពុជា។

យើងខ្ញុំជំរុញឲ្យពលរដ្ឋកម្ពុជាចូលរួមពាក់ព័ន្ធនឹងកិច្ចពិភាក្សាជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតទាក់ទងទៅនឹងច្បាប់ទាំងនេះ ហើយថ្លែងចេញនូវក្តីកង្វល់របស់ពួកគេទៅដល់អ្នកតំណាង ដែលត្រូវបានជ្រើសតាំងរបស់ខ្លួន។


**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:**

១. កញ្ញា ស៊ិន ពុទ្ធារី នាយកផ្នែកទំនាក់ទំនងនិងអភិវឌ្ឍន៍សមាជិក នៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
putheary.sin@ccc-cambodia.org, ០១២ ៧៦៩ ៨៣៦

២. លោក ប៉ិច ពិសី នាយកកម្មវិធីនៃអង្គការតម្លាភាពកម្ពុជា (TIC)
piseypech@ticambodia.org, ០៨៩ ៩៧២ ៦២០

៣. លោក ឡាំ សុជាតិ នាយករងនៃវិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ (API)
socheatlam@apiinstitute.org, ០១២ ៧១៨ ៦១១

៤. លោក សួន ប៊ុនស័ក ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
suonbunsak.chrac@yahoo.com, ០៩២ ៣៤៤ ៣៥៧

៥. លោក សៀ ភារម្យ ប្រធានក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF)
cam.hrtf@gmail.com, ០១២ ៨៥២ ៣២៥

៦. លោក ឌុច ពិសិដ្ឋ អ្នកសម្របសម្រួលគម្រោងនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
duchpiseth@cchrcambodia.org, ០១២ ៧១២ ៣៧១